**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៦៩ អនក្រ. បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតអង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់

—— ✧ ——

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## ស ម្រេ ច

**មាត្រា ១.-**

បង្កើតអង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់មួយ ក្រោមការគ្រប់គ្រងនៃអគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា ២.-**

អង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ ជាសេនាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពកំណែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ដែលមានជាអាទិ៍÷

- ការកសាងច្បាប់តាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
- ការចូលរួមរៀបចំការងារ ពង្រឹងសមត្ថភាព កសាងច្បាប់ នៅតាមស្ថាប័នរដ្ឋ និងតាមរយៈសិក្ខាសាលា
- ការតាមដានត្រួតពិនិត្យ និងជំរុញការងារកសាងច្បាប់ តាំងពីដើមទីរហូតដល់ការប្រកាសឱ្យប្រើ
- ការសម្របសម្រួលនៅកម្រិតការផ្តួចផ្តើមកសាងច្បាប់ រវាងអង្គភាព ក្រសួង ស្ថាប័ន និងអង្គការអន្តរជាតិ ឬប្រទេសអ្នកផ្តល់ជំនួយក្នុងវិស័យកំណែទម្រង់ច្បាប់
- ការបង្ក និងរៀបចំឱ្យមានការចូលរួមផ្តល់យោបល់ពីអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលនានា
- ការសម្រួល និងពិនិត្យឡើងវិញនូវទម្រង់ ការបកប្រែ ឃ្លោងឃ្លា និងការប្រើពាក្យពេចន៍ នៃសេចក្តីព្រាងចុងក្រោយ
- ការផ្សព្វផ្សាយច្បាប់ និងវិធានសំខាន់ៗជាទូទៅក្នុងទូទាំងប្រទេស រួមមានការរៀបចំ និងចែកចាយរាជកិច្ច ព្រមទាំងឯកសារពាក់ព័ន្ធផ្លូវការចាំបាច់ទាំងឡាយ
- ការងាររដ្ឋបាល និងហិរញ្ញកិច្ចរបស់អង្គភាព
- ការអនុវត្តរាល់ភារកិច្ច ដែលប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលប្រគល់ឱ្យ ។

**មាត្រា ៣.-**

អង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ មានការិយាល័យរដ្ឋបាល និងហិរញ្ញកិច្ចមួយ ដើម្បីបម្រើកិច្ចដំណើរការរបស់ខ្លួន ។ ការិយាល័យរដ្ឋបាល និងហិរញ្ញកិច្ចនេះ ត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាភិបាលកំណែទម្រង់រដ្ឋបាល ។

**មាត្រា ៤.-**

សមាសភាព នៃអង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ ត្រូវជ្រើសរើសក្នុងចំណោមសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃរាជរដ្ឋាភិបាល ។ អង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ អាចស្នើសុំប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ឱ្យអញ្ជើញអ្នកច្បាប់ពីបណ្តាអង្គភាពឯកជននានា ស្ថាប័ន និងពីអង្គការក្រៅរដ្ឋាភិបាល មកបំពេញការងារជាអ្នកជំនាញការឱ្យអង្គភាពនេះ ។

**មាត្រា ៥.-**

អង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ ត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនអគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្នុងករណីពិសេស ជូនប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា ៦.-**

អង្គភាពទទួលបន្ទុកកំណែទម្រង់ច្បាប់ មានសមាសភាពដូចតទៅ :

ឯកឧត្តម **សំ សុខផល** ជាប្រធាន

ឯកឧត្តម **ឡេង ប៉េងឡុង** អនុប្រធាន

ឯកឧត្តម **ក្រាញ់ ជ័យឈាតិតូនី** សមាជិក

ឯកឧត្តម **ស៊ុយ ម៉ុងលាង** សមាជិក

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងមាត្រា ៦ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០០២

[ត្រា] ...សេន

**បានយកសេចក្តីគោរពជូនសម្តេចនាយករដ្ឋមន្ត្រី**

**"ដើម្បីសុំហត្ថលេខា"**

**ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

[ហត្ថលេខា]

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

៦